# ព័ត៌មានទូទៅ

តំបន់ដីសើមស្ទឹងសែនមានទីតាំងស្ថិតនៅប៉ែកអាគ្នេយ៍នៃបឹងទន្លេសាបក្នុងឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់ដីសើមស្ទឹងសែន គឺជាតំបន់ស្នូលមួយក្នុងចំណោមតំបន់ស្នូលទាំងបីនៃបបនីយជីវៈមណ្ឌលបឹងទន្លេសាប និងជាតំបន់សត្វស្លាប និងជីវៈចម្រុះសំខាន់ៗនៅក្នុងប្រទេសកម្ពុជា។

## ផែនទី






# តើអ្វីទៅជាអនុសញ្ញារ៉ាមសារ

"អនុសញ្ញាតំបន់ដីសើម ឬអនុសញ្ញារ៉ាមសារ ( បង្កើតនៅក្រុងរ៉ាមសារ ប្រទេសអ៊ីរ៉ង់ ក្នុងឆ្នាំ១៩៧១) គឺជាសន្ធិសញ្ញាអន្តរដ្ឋាភិបាល ដែលផ្ដល់នូវយន្តការសម្រាប់ធ្វើសកម្មភាពនៅថ្នាក់ជាតិ និងសហប្រតិបត្តិការជាអន្តរជាតិក្នុងការអភិរក្ស និងប្រើប្រាស់តំបន់ដីសើម និងធនធានរបស់វាដោយឈ្លាសវៃ។ ប្រទេសកម្ពុជាបានអនុម័តយល់ព្រមលើអនុសញ្ញារ៉ាមសារកាលពីថ្ងៃទី២៤ខែធ្នូ ឆ្នាំ១៩៩៦ និងបានចូលជាសមាជិកពេញសិទ្ធនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩៩។"

▶ តំបន់រ៉ាមសារ គឺជាតំបន់ដីសើមដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យនៃតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិយ៉ាងតិចមួយ។

▶ តំបន់រ៉ាមសារថ្មី៖ តំបន់ដីសើមស្ទឹងសែន ត្រូវនឹងលក្ខណៈវិនិច្ឆ័យទី២ (ប្រភេទសត្វកម្រ និងកំពុងរងគ្រោះ) លក្ខណៈវិនិច្ឆ័យទី៣ (ជីវចម្រុះ) លក្ខណៈវិនិច្ឆ័យទី៤ (វដ្ដនៃជីវិត និងជម្រក) លក្ខណៈវិនិច្ឆ័យទី៦ (ចំនួនសត្វស្លាបទឹកច្រើនជាង១%) និងលក្ខណៈវិនិច្ឆ័យទី៨ (កន្លែងពងកូន និងផ្សេងៗ)។

(សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រតំបន់រ៉ាមសារ៖ http://www.ramsar.org)



# ផែនទីបង្ហាញផ្លូវទៅតំបន់ដីសើមស្ទឹងសែន



ស្នាក់ការតំបន់ស្នូលស្ទឹងសែន




# ទំនាក់ទំនងព័ត៌មាន៖

**ការិយាល័យនៅខេត្តកំពង់ធំ៖**

លោក ស៊ន ពិផាត (នាយកតំបន់ស្នូលស្ទឹងសែន)

ទីស្នាក់ការល្បាតតំបន់ស្នូលស្ទឹងសែន ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទទំនាក់ទំនង៖ ០៩៥ ៨៣៣ ២២៩

ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ និង ១៣:០០ ដល់ ១៧:០០

**ការិយាល័យនៅរាជធានីភ្នំពេញ៖**

លោក ប៊ុច ម៉ូរ៉ាន់ (ប្រធានការិយាល័យ)

នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន (ជាន់ទី២) អាគារមរតកតេជោ (ដីឡូលេខ៥០៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទទំនាក់ទំនង៖ ០១២ ៤២០ ៨៦៨

អ៊ីម៉ែល៖ moran_wcd@yahoo.com

BirdLife INTERNATIONAL

環境省 Ministry of the Environment Government of Japan



# តំបន់ដីសើមស្ទឹងសែន

## រស់នៅសុខដុមជាមួយតំបន់ដីសើមស្ទឹងសែន



## ភាពសម្បូរបែបនៃជីវៈចម្រុះ

**ប្រព័ន្ធជលសាស្ត្រ៖** តំបន់ដីសើមស្ទឹងសែនគឺជាផ្នែកមួយនៃបឹងទន្លេសាបដែលទទួលរងឥទ្ធិពលខ្លាំងពីការផ្លាស់ប្តូរចរន្តទឹករវាងទន្លេមេគង្គ ទន្លេស្ទឹងសែន និងបឹងទន្លេសាប។ វដ្តទឹកជំនន់ប្រចាំឆ្នាំបានបណ្តាលឱ្យមានការប្រែប្រួលទៅលើកំពស់ទឹក ដែលបានទ្រទ្រង់ដល់សត្វ និងរុក្ខជាតិសំខាន់ៗក៏ដូចជាផ្តល់នូវផលិតផលជលផលដ៏ច្រើន។

**ប្រភេទរុក្ខជាតិសំខាន់ៗ៖** វដ្តទឹកបានទ្រទ្រង់ដល់ប្រភេទរុក្ខជាតិលិចទឹកតាមរដូវសំខាន់ៗដូចជា ព្រៃដុះតាមដងទន្លេស្ទឹងសែន ព្រៃគម្លោច និងវាលស្មៅ។

**ប្រភេទសត្វ៖** យ៉ាងហោចណាស់មានវត្តមាននៃថនិកសត្វ ៩ ប្រភេទ សត្វស្លាប ៧៩ ប្រភេទ សត្វអណ្តើក ៤ ប្រភេទ និងត្រីចំនួន ៩៤ ប្រភេទនៅតំបន់ដីសើមស្ទឹងសែន។ ក្នុងនោះមានវត្តមានប្រភេទសត្វជិតផុតពូជជាសកលមួយចំនួនដូចជា ស្វាព្រាម (Silvered Langur) ភេរោមច្រមុះ (Hairy-noised Otter) សត្វត្រដក់តូច (Lesser Adjutant) អណ្តើកសង្កល់ (Yellow-head Temple Turtle) ត្រីគល់រាំង (Mekong Giant Barb) ត្រីប្រាធំ (Striped Catfish) និងត្រីត្រសក់ក្រហម (Isok Barb) (អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំកម្ពុជា, ២០១៦)។

**ផ្តល់ជម្រក និងជាកន្លែងដ៏មានសុវត្ថិភាពសម្រាប់ជីវចម្រុះជាច្រើន៖** តំបន់នេះក៏ផ្តល់ជាទីកន្លែងដ៏សំខាន់សម្រាប់ពងកូន ជាផ្លូវទឹកសម្រាប់ឱ្យប្រភេទត្រីមួយចំនួនផ្លាស់ទី ជាកន្លែងរកចំណីរបស់សត្វស្លាបជាច្រើន និងជាទីជម្រកដ៏សំខាន់សម្រាប់ថនិកសត្វជាច្រើន។

## សេវាកម្មប្រព័ន្ធអេកូឡូស៊ី

ប្រជាជនមូលដ្ឋានដែលរស់នៅតំបន់ដីសើមស្ទឹងសែន គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានជលផលរួមមាន ទឹក និងចំណីអាហារ (ជាពិសេសគឺការនេសាទ និងកសិកម្ម) ដែលបានពីតំបន់ដីសើមស្ទឹងសែនដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ តំបន់ដីសើមក៏ផ្តល់សេវាកម្មផ្សេងៗផងដែរ រួមមាន រក្សាលំនឹងវដ្តអាកាសធាតុ ស្តុកកាបូន ចាក់បំពេញទឹកក្រោមដី បន្សុតទឹក ការពារសំណឹក កំណរដីល្បាប់ និងគ្រប់គ្រងទឹកជំនន់ និងខ្យល់ព្យុះ។

តំបន់ដីសើម ក៏ជាកន្លែងសក្តានុពលមួយដ៏សំខាន់ផ្នែកទេសចរណ៍ធម្មជាតិ។


សកម្មភាពនេសាទ


ប្រជានេសាទធ្វើដំណើរទៅកន្លែងនេសាទ


ផ្ទះបណ្តែតទឹកនៅតំបន់ដីសើមស្ទឹងសែន


ត្រដក់តូច (ប្រភេទសត្វកំពុងរងគ្រោះ)


ចង្កៀលខ្យង (ប្រភេទសម្បូរ)


ស្វាពាម(ប្រភេទសត្វជិតផុតពូជ)


ទុងប្រផេះ (ប្រភេទសត្វជិតរងគ្រោះ)

## កត្តាគម្រាមកំហែង

*មានកត្តាគម្រាមកំហែងមួយចំនួនដែលជះឥទ្ធិពលលើតំបន់ដីសើមស្ទឹងសែន។*

- **ការសឹករិចរិលនៃទីជម្រក៖** ភ្លើងឆេះព្រៃ ការដុត និងកាប់រានព្រៃសម្រាប់យកដីធ្វើកសិកម្ម និងធ្វើផ្លូវទៅបរបាញ់ និងនេសាទ។
- **ការបរបាញ់ និងដាក់អន្ទាក់៖** ការបំពុលសត្វស្លាបតាមមាត់បឹង ការសម្លាប់សត្វភេដែលជាប្រភេទសត្វកំពុងរងគ្រោះដើម្បីយកស្បែក ការដាក់អន្ទាក់ និងប្រើប្រាស់សម្លេងដើម្បីចាប់សត្វស្លាបដែលជាប្រភេទកំពុងរងគ្រោះ។
- **ការប្រមូលផលពីធនធានធម្មជាតិច្រើនលើសលុប៖** ការនេសាទខុសច្បាប់ និងការនេសាទពេញមួយឆ្នាំរួមទាំងរដូវត្រីពង។


ស្បែកសត្វភេ


ព្រៃដែលបានឆេះនៅតំបន់ស្ទឹងសែន




## ការអភិរក្សតំបន់ដីសើម

វិធានការមួយសំខាន់សម្រាប់ការអភិរក្សតំបន់ដីសើម គឺដាក់បញ្ចូលតំបន់ដែលសម្បូរជីវៈចម្រុះជាតំបន់ការពារ (តំបន់រ៉ាមសារ) ដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ដោយឈ្លាសវៃពីភាគីពាក់ព័ន្ធនានាក្នុងការគ្រប់គ្រងតំបន់ដីសើម។

**"ការប្រើប្រាស់ដោយឈ្លាសវៃ" នៃតំបន់ដីសើម ៖** វាជាការសំខាន់ខ្លាំងណាស់ក្នុងការប្រើប្រាស់តំបន់ដីសើមប្រកបដោយចីរភាព ដើម្បីរក្សានូវមុខងារ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ដីសើម។

**ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនានា៖** វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធដែលមកពីស្ថាប័នផ្សេងៗគ្នាដូចជាប្រជាជនមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាដើម -ល- ដើម្បីជៀសវាងជម្លោះនានា ធ្វើការសម្រេចចិត្តល្អប្រសើរជាងមុននិងចែករំលែកផលប្រយោជន៍។